# សេចក្តីថ្លែងការណ៍រួម

រាជធានីភ្នំពេញ ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៥

## សង្គមស៊ីវិលសូមអំពាវនាវឱ្យបញ្ចប់និទណ្ឌភាពនៅកម្ពុជាក្នុងឱកាសទិវាបញ្ចប់និទណ្ឌភាពអន្តរជាតិចំពោះបទល្មើសប្រឆាំងទៅលើអ្នកសារព័ត៌មាន

ដើម្បីប្រារព្ធទិវាបញ្ចប់និទណ្ឌភាពអន្តរជាតិចំពោះបទល្មើសប្រឆាំងអ្នកសារព័ត៌មានលើកទីពីររបស់អង្គការសហប្រជាជាតិ យើងខ្ញុំជាអង្គការសង្គមស៊ីវិលដែលមានរាយនាមដូចខាងក្រោមសូមអំពាវនាវឱ្យរាជរដ្ឋាភិបាលកម្ពុជាបញ្ចប់វប្បធម៌និទណ្ឌភាពជាដដែលៗនៅកម្ពុជា និងត្រូវធានាថាជនប្រព្រឹត្តរំលោភសិទ្ធិមនុស្សត្រូវបាននាំខ្លួនមកផ្តន្ទាទោស។

សេចក្តីថ្លែងការណ៍រួមនេះធ្វើឡើងមួយសប្តាហ៍បន្ទាប់ពីមានការវាយប្រហារដោយហិង្សាទៅលើអ្នកតំណាងរាស្ត្រគណបក្សជំទាស់គឺលោក ញ៉យ ចំរើន និងលោក គង់ សភា កាលពីថ្ងៃច័ន្ទកន្លងទៅនេះក្នុងអំឡុងពេលការតវ៉ាទាមទារឱ្យមានការដកតំណែងអនុប្រធានគណបក្សសង្គ្រោះជាតិ ("គ.ស.ជ") លោក កឹម សុខា ចេញពីតំណែងជាអនុប្រធានទី១ នៃរដ្ឋសភានៅខាងក្រៅវិមានរដ្ឋសភា។ អ្នកនយោបាយទាំងពីររូបត្រូវបានអ្នកតវ៉ាវាយឱ្យរងរបួសយ៉ាងដំណំក្នុងអំឡុងពេលតវ៉ា ដែលលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានព្យាករណ៍ជាមុន។ ភាគច្រើនអ្នកតវ៉ាទាំងនោះសុទ្ធតែជាអ្នកគាំទ្រគណបក្សប្រជាជនកម្ពុជាដែលដឹកនាំដោយមន្ត្រីសន្តិសុខស្លៀកពាក់ឯកសណ្ឋានស៊ីវិល ។ បើទោះជាមានអំពើហិង្សាកើតឡើងបន្ទាប់ពីការតវ៉ាក៏ដោយ ក៏អាជ្ញាធរមិនបានចាត់វិធានការរក្សាសណ្តាប់ធ្នាប់ដើម្បីការពារដល់ជនរងគ្រោះឡើយ ហើយរហូតមកដល់ពេលនេះ ជនដៃដល់មិនទាន់ត្រូវបានអាជ្ញាធរកំណត់អត្តសញ្ញាណនៅឡើយទេ។

ខណៈដែលលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានអំពាវនាវជាសាធារណៈឱ្យចាប់ខ្លួនជនដែលទទួលខុសត្រូវចំពោះអំពើហិង្សាទៅលើអ្នកតំណាងរាស្ត្រទាំងពីររូបរបស់គ.ស.ជ គេមិនទាន់ដឹងច្បាស់ថាតើអាជ្ញាធរនឹងធានាឱ្យមានការស៊ើបអង្កេតជាបន្ទាន់និងដោយឯករាជ្យដែលអាចចាប់ខ្លួនជនដៃដល់យ៉ាងណានោះទេ ជាពិសេសផ្តល់នូវកំណត់ហេតុស៊ើបអង្កេតក្នុងការធានានូវយុត្តិធម៌ដល់ជនរងគ្រោះដែលបានកើតឡើងជាងបីទសវត្សរ៍កន្លងមកនេះ។

អ្នកសារព័ត៌មានកម្ពុជា គឺជាជនរងគ្រោះច្រើនជាងគេក្នុងចំណោមជនរងគ្រោះដទៃទៀតនៃករណីនិទណ្ឌភាព ។ នៅពេលអ្នកសារព័ត៌មាននៅកម្ពុជាលើកបង្ហាញនូវទង្វើខុសឆ្គងរបស់រដ្ឋាភិបាលនិងវិស័យឯកជនអ្នកទាំងនោះតែងតែប្រឈមនឹងការគំរាមដល់អាយុជីវិត និងសម្លាប់ ជាក់ស្តែងមានអ្នកសារព័ត៌មានចំនួន ១៣ រូបត្រូវបានសម្លាប់តាំងពីឆ្នាំ១៩៩៤ និងករណីថ្មីបំផុតបានកើតឡើងនៅក្នុងខែតុលា ឆ្នាំ២០១៤។ ក្នុងចំណោមទាំង ១៣ ករណីនោះ មានតែពីរករណីប៉ុណ្ណោះដែលត្រូវបានកាត់ទោសដោយជោគជ័យ រីឯជនល្មើសនៃ ១១ ករណីផ្សេងទៀតមិនត្រូវបាននាំខ្លួនមកផ្តន្ទាទោសនោះទេ។ ស្រដៀងគ្នានេះផងដែរ អ្នកសារព័ត៌មានកម្ពុជាតែងទទួលរងការបំពាបំពាន ការគំរាមគំហែង និងការបំភិតបំភ័យយ៉ាងព្រៃផ្សៃពីសំណាក់នគរបាលនិងកងកម្លាំងសន្តិសុខ ហើយជនប្រព្រឹត្តិតែងត្រូវបានរួចគេចផុតពីភាពយុត្តិធម៌ទៅវិញ។ នៅខែឧសភា ឆ្នាំ២០១៤ លោក

ឡាយ សាមាន និង តាត ឧត្តម ដែលជាអ្នកសារពត៌មានរបស់វិទ្យុសម្លេងប្រជាធិបតេយ្យ ("វីអូឌី") ត្រូវកងសន្តិសុខខ័ណ្ឌដូនពេញវាយប្រហារក្នុងរាជធានីភ្នំពេញ។ អ្នកទាំងពីរបានរាយការណ៍ពីការជួបប្រជុំដោយសន្តិវិធីដែលគ.ស.ជ រៀបចំឡើងជាផ្នែកមួយនៃយុទ្ធនាការឃោសនាបោះឆ្នោតរបស់ខ្លួន។ នៅខែសីហា ឆ្នាំ២០១៥ អ្នកសារពត៌មានរបស់វីអូឌីពីរនាក់ផ្សេងទៀតគឺលោក យុត សុគន្ធ និងលោក ហេង វិចិត្រ ត្រូវបានកងកម្លាំងសន្តិសុខនៅរាជធានីភ្នំពេញគំរាមគំហែងនិងបំពាបំពានម្តងទៀត ខណៈដែលយកព័ត៌មានពីការតវ៉ារបស់សកម្មជនដីធ្លីបឹងកក់។ គ្មានការស៊ើបអង្កេតណាមួយទៅលើសកម្មភាពរបស់កងកម្លាំងសន្តិសុខ និងទៅលើករណីទាំងពីរនោះទេ។

វប្បធម៌និទណ្ឌភាពដ៏រាលដាលនៅកម្ពុជាត្រូវបានលើកបង្ហាញតាមរយៈការឆ្លើយតបនាពេលថ្មីៗនេះរបស់អាជ្ញាធរកម្ពុជាទៅនឹងការអំពាវនាវរបស់អង្គការសង្គមស៊ីវិលស្នើឱ្យធ្វើការស៊ើបអង្កេតចំពោះករណីសម្លាប់លោក ម៉ៅ សុខចាន់អាយុ ២៩ ឆ្នាំដែលត្រូវបានបាញ់សម្លាប់ បន្ទាប់ពីលោកជាប់កកស្ទះនៅក្នុងក្រុមអ្នកតវ៉ាក្រោយការបោះឆ្នោតឆ្នាំ ២០១៣ ខណៈដែលលោកកំពុងធ្វើដំណើរទៅកន្លែងធ្វើការ។ ឃាតកដែលបានសម្លាប់លោកនៅរួចខ្លួន ហើយមិនត្រូវបានអាជ្ញាធរនាំយកមកផ្តន្ទាទោសនៅឡើយទេ។ បន្ទាប់ពីមានការអំពាវនាវឱ្យធ្វើការស៊ើបអង្កេតចំពោះករណីសម្លាប់លោក សុខចាន់កាលពីខែមុន អ្នកនាំពាក្យក្រសួងមហាផ្ទៃលោកខៀវ សុភ័ក្របានប្រកាសថាករណីនោះគួរតែត្រូវបាន *"កប់ចោល"* ដែលនេះជាការបង្ហាញឱ្យឃើញពីចេតនារបស់រដ្ឋាភិបាលចំពោះករណីនិទណ្ឌភាពដ៏រាលដាលនៅកម្ពុជា។

ដូចគ្នានឹងអ្នកសារព័ត៌មាន ជនរងគ្រោះដ៏លេចធ្លោនៃករណីនិទណ្ឌភាពរួមមានលោក ឈុត វុទ្ធី លោក ជា វិជ្ជា លោកខឹម សុផាត និងលោក ម៉ៅ សុខចាន់ គ្រាន់តែឧទាហរណ៍ក្នុងចំណោមករណីនិទណ្ឌភាពជាច្រើនផ្សេងទៀតនៅកម្ពុជា ដែលមានអ្នកសារព័ត៌មាន សកម្មជន អ្នកការពារបរិស្ថាន សហជីព អ្នកការពារសិទ្ធិមនុស្ស និងប្រជាពលរដ្ឋនៅទូទាំងប្រទេសកម្ពុជាដែលសិទ្ធិរបស់ពួកគាត់ត្រូវបានរំលោភបំពានយ៉ាងធ្ងន់ធ្ងរ រីឯជនល្មើសបែរជាមិនទទួលបានការផ្តន្ទាទោសណាមួយឡើយ។

ពេលនេះគឺក្នុងឱកាសល្អបំផុតដែលត្រូវរំលឹករដ្ឋាភិបាលមិនត្រូវបំភ្លេចចោលចំពោះជនរងគ្រោះនៃករណីនិទណ្ឌភាពដែលត្រូវបានសម្លាប់ឬឃាយីផ្សេងៗ ហើយមិនទាន់ទទួលបានយុត្តិធម៌ពីសំណាក់អាជ្ញាធរកម្ពុជានោះឡើយ។

យើងខ្ញុំជាអង្គការសង្គមស៊ីវិលដែលមានរាយនាមខាងក្រោម សូមថ្កោលទោសលើករណីនិទណ្ឌភាពជាដដែលៗដែលកំពុងរាលដាលនៅកម្ពុជា និងសូមអំពាវនាវរដ្ឋាភិបាលកម្ពុជាធានានូវយុត្តិធម៌ដល់ជនរងគ្រោះនិងក្រុមគ្រួសាររបស់ពួកគាត់ ដូចបានធានាក្រោមច្បាប់ជាតិ និងច្បាប់អន្តរជាតិ។

**អង្គការសង្គមស៊ីវិលដែលបានគាំទ្រសេចក្តីថ្លែងការណ៍រួមនេះមានដូចខាងក្រោម ៖**

| *ល.រ* | *ឈ្មោះ* | *ឈ្មោះ* | *លេខទូរស័ព្ទ* |
|---|---|---|---|
| ១ | *ក្រុមការងារដើម្បីដោះស្រាយទំនាស់ (ACT)* | *កញ្ញា ស្រី សុធាវី* | 017 990 371 |
| ២ | *សហព័ន្ធសហជីពកម្មករសំណង់ និងព្រៃឈើកម្ពុជា* | *លោក វ៉ាន់ ថុល* | 012 752 617 |

| | | | |
|---|---|---|---|
| ៣ | សម្ព័ន្ធសហជីពកម្ពុជា (CATU) | លោកស្រី យ៉ាង សោភណ្ឌ | 012 880 089 |
| ៤ | មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR) | លោកស្រី ចក់ សុភាព | 011 943 213 |
| ៥ | គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃអង្គការ សមាគមការពារសិទ្ធិមនុស្សកម្ពុជា (CHRAC) | លោក សួន ប៊ុនស័ក្តិ | 092 344 357 |
| ៦ | សមាគមអាដហុកការពារសិទ្ធិមនុស្សនិងការអភិវឌ្ឍន៍នៅកម្ពុជា (ADHOC) | លោក នី ចរិយា | 011 274 959 |
| ៧ | សហភាពការងារកម្ពុជា (CLC) | លោក អាត ធន់ | 012 998 906 |
| ៨ | សម្ព័ន្ធជំរឿននិងការពារសិទ្ធិមនុស្សលីកាដូ (LICADHO) | លោកស្រី ណារី ពីលូក | 012 803 650 |
| ៩ | សម្ព័ន្ធដើម្បីសុចរិតភាពនិងគណនេយ្យភាពសង្គម (CISA) | លោក ហឹម យន់ | 012 947 022 |
| ១០ | សម្ព័ន្ធសហគមន៍កសិករកម្ពុជា (CCFC) | លោក ថេង សាវឿន | 015 225 088 |
| ១១ | មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ (CLEC) | លោក ហួន ជុនឌី | 093 345 602 |
| ១២ | អង្គការសមធម៌កម្ពុជា (EC) | លោក អៀង វុទ្ធី | 012 791 700 |
| ១៣ | សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA) | លោក វន់ ពៅ | 012 534 796 |
| ១៤ | សមាគម ឥន្ទ្រទេវី (IDA) | លោកស្រី ឌី រដ្ឋា | 012 897 161 |
| ១៥ | គណៈកម្មាធិការអព្យាក្រឹត និងយុត្តិធម៌ ដើម្បីការបោះឆ្នោតដោយសេរី និងត្រឹមត្រូវនៅកម្ពុជា (NICFEC) | លោក សំ គន្ធាមី | 012 822 273 |
| ១៦ | មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព (PDP-Center) | លោក យ៉ង់ គឹមអេង | 012 828 211 |
| ១៧ | អង្គការពន្លកខ្មែរ | លោក អាង ជាតិឡោម | 012 517943 |
| ១៨ | សមាគមជាងត្នោត (STT) | លោក អ៊ី សារុំ | 012 836 533 |
| ១៩ | អង្គការស្ត្រីខ្មែរ (SK) | លោកស្រី អរុណ រស្មី | 012 236 653 |
| ២០ | អង្គការកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន(YRDP) | លោក ជាង សុខា | 011 928 416 |
| ២១ | អង្គការមោតាធម្មជាតិ (MN) | លោក អាឡិច ហ្គូស្សាលេស ដាវីសុន | N/A |
| ២២ | បណ្តាញយុវជនកម្ពុជា (CYN) | លោក ទឹម ម៉ាឡៃ | 017 990 689 |